**សូមគោរពភ្ញៀវជាតិនិងអន្តរជាតិជាទីគោរពដ៏ខ្ពង់ខ្ពស់,**

**សូមគោរពឯកឧត្តម   លោកជំទាវ លោក លោកស្រីនិងអ្នកនាងកញ្ញា**

**ជាទីគោរពនិងជាទីស្នេហា,**

ក្នុងឱកាសដ៏មហោឡារិកនេះ  ខ្ញុំបាទ**គង់ វន** សូមសំដែងនូវអំណរគុណដ៏ជ្រាលជ្រៅបំផុតចំពោះភ្ញៀវជាតិ  និងអន្តរជាតិគ្រប់លំដាប់ថ្នាក់  ដែលបានលះបង់ពេលវេលាដ៏មានតម្លៃអញ្ជើញមកចូលរួមអបអរសាទរដល់រូបខ្ញុំបាទក្នុងពិធីប្រគល់គ្រឿងឥស្សរិយសព្រះចៅអធិរាជជប៉ុន“The Order of the Rising Sun, Gold Rays with Rosette”ដល់រូបខ្ញុំបាទក្នុងនាមជាប្រធានមូលនិធិខ្មែរជំនួយការសិក្សា  និងជាប្រធានក្រុមប្រឹក្សាភិបាលអនុនិងវិទ្យាល័យមិត្តភាពខ្មែរ-ជប៉ុន   និងជាអ្នកផ្តើមគំនិតបង្កើតគ្រឹះស្ថានសិក្សាមួយនេះ។

**ភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិជាទីគោរព,**

ខ្ញុំបាទមានសេចក្តីរំភើបរីករាយឥតឧបមា  ពេលទទួលដំណឹងមកថានៅថ្ងៃទី០៣ខែវិច្ឆិកាឆ្នាំ២០១៤ រដ្ឋាភិបាលជប៉ុនបានប្រកាសជាផ្លូវការនូវឈ្មោះជនបរទេសចំនួន៥៧នាក់  ដែលត្រូវបានទទួលបានគ្រឿងឥស្សរិយសនៃព្រះចៅអធិរាជជប៉ុន ក្នុងចំនួននោះក៏មានឈ្មោះរូបខ្ញុំបាទផងដែរ។

ពីមុនមកខ្ញុំមិនដែលនឹកស្រមៃថា  នឹងទទួលបានកិត្តិយសដ៏ធំធេងក្រៃលែងបែបនេះឡើយ។ក៏ប៉ុន្តែបើគិតទៅតាមការខិតខំប្រឹងប្រែងរបស់ខ្ញុំកន្លងមក      ហេតុការណ៍នេះពិតជាបានមកពីសុឆន្ទៈរបស់ខ្ញុំផ្ទាល់ក្នុងការបំពេញគ្រប់ការងារតាំងពីអតីតកាលរហូតដល់បច្ចុប្បន្នកាល។

១.នៅក្នុងឆ្នាំ១៩៧០ដល់១៩៧៥ ខ្ញុំបានធ្វើការឱ្យទីភ្នាក់ងារពត៌មានជប៉ុនKyodoNews នៅក្នុងប្រទេ-សកម្ពុជា ដោយបានធ្វើរបាយការណ៍ដ៏ជាក់លាក់  និងទាន់ហេតុការណ៍អំពីស្ថានភាពឥណ្ឌូចិនជូនប្រជាជនជប៉ុនជ្រាប។

២.ក្នុងឆ្នាំ១៩៨១ខ្ញុំបាទ  និងក្រុមគ្រួសារបានភៀសខ្លួនទៅរស់នៅប្រទេសជប៉ុន។ប្រទេសនេះជាប្រទេ-សរីកចំរើនជឿនលឿនគ្រប់វិស័យ      ពិសេសវិស័យអប់រំនិងសេដ្ឋកិច្ច។ដោយចង់ឃើញមាតុភូមិរបស់ខ្លួនដើរតាមគំរូល្អៗរបស់ប្រទេសជប៉ុន       នៅឆ្នាំ១៩៩៣ ខ្ញុំបានបង្កើតមូលនិធិមួយនៅទីនោះឈ្មោះថា"មូលនិធិខ្មែរជំនួយការសិក្សាដើម្បីប្រមែប្រមូលថវិកាពីបងប្អូនអណិកជនខ្មែរឯទៀតៗ  ពិសេសពីមិត្តភក្តិនិងសប្បុរសជនជប៉ុនជាច្រើនមកជួយកសាងអាគារសិក្សាបានចំនួន៤ខ្នង នៅស្រុកព្រះស្តេចនិងស្រុកកំពង់ត្របែក   ខេត្តព្រៃវែង។

៣.ខ្ញុំមានការស្រមើស្រមៃចង់ឃើញប្រព័ន្ធអប់រំនៅកម្ពុជាមានការកែលំអ សម្របសម្រួលទៅតាមលំនាំប្រព័ន្ធអប់រំតាមបែបប្រទេសជប៉ុន ទើបនៅឆ្នាំ១៩៩៨អង្គការCEAFយើងខ្ញុំបានចុះអនុស្សរណៈនៃកិច្ចព្រមព្រៀងជាមួយក្រសួងអប់រំ យុវជន និងកីឡា សហការគ្រប់គ្រងគ្រឹះស្ថានមធ្យមសិក្សាមួយដែលនឹងត្រូវបង្កើតក្នុងពេលខាងមុខ។

៤.ក្នុងឆ្នាំ១៩៩៩ខ្ញុំបានបង្កើតអនុវិទ្យាល័យមិត្តភាពខ្មែរ-ជប៉ុនស្ថិតលើដីមួយកន្លែងទំហំជិត៥ហិចតា។ បីឆ្នាំក្រោយមកអនុវិទ្យាល័យនេះបានក្លាយទៅជាវិទ្យាល័យមិត្តភាពខ្មែរ-ជប៉ុន។

៥.ចាប់តាំងពីសាលារៀននេះដំណើរការមក ខ្ញុំបានអញ្ជើញគ្រូស្ម័គ្រចិត្តភាសាជប៉ុនមកបង្រៀនភាសាជប៉ុននៅអនុវិទ្យាល័យមិត្តភាពខ្មែរ-ជប៉ុន គឺជាសាលារៀនតែមួយគត់នៅប្រទេសកម្ពុជាដែលមានកាលវិភាគបង្រៀនភាសាជប៉ុនហើយចំនួនយុវជន យុវនារីដែលចេះនិយាយភាសាជប៉ុនត្រូវបានកើនឡើងជារៀងរាល់ឆ្នាំ។

៦.ខ្ញុំមានសេចក្តីអំណរគុណ និងពេញចិត្តបំផុតចំពោះប្រព័ន្ធអប់រំជប៉ុនដែលជំរុញឱ្យខ្ញុំខិតខំបានដកស្រង់បទពិសោធន៍ល្អៗមកអនុវត្តនៅក្នុងអនុនិងវិទ្យាល័យមិត្តភាពខ្មែរ-ជប៉ុនយើងនេះ។

៧.ជារៀងរាល់ឆ្នាំខ្ញុំបានបង្កើតឱ្យមានកម្មវិធីបំលាស់ប្តូរយុវជន រវាងកម្ពុជានិងជប៉ុននិងបានដើរតួនាទីជាអ្នកដឹកនាំដ៏សំខាន់ ក្នុងការលើកកំពស់ការយល់ដឹងអំពីគ្នាទៅវិញទៅមកនិងចំណងមិត្ត ភាពរវាងប្រទេសទាំងពីរ។

និយាយរួមលទ្ធភាពសំខាន់បំផុតដែលនាំឱ្យខ្ញុំបាទទទួលបានកិត្តិយសដ៏កម្រនាពេលនេះគឺដោយការទទួលស្គាល់ពីរដ្ឋាភិបាលជប៉ុន លើការចូលរួមចំណែកដ៏ធំធេងរបស់ខ្ញុំដល់ការអភិវឌ្ឍន៍ការអប់រំភាសាជប៉ុននិងការពង្រឹងពង្រីកការយល់ដឹងអំពីគ្នាទៅវិញទៅមករវាងប្រទេសជប៉ុននិងប្រទេសកម្ពុជា។

ទោះជាយ៉ាងនេះក៏ដោយខ្ញុំយល់ថាបើពុំមានការជួយជ្រោមជ្រែងពេញទំហឹងពីមិត្តភក្តិជប៉ុនពីសប្បុរសជនជប៉ុនមួយផ្នែកនិងពីសំណាក់លោកគ្រូ អ្នកគ្រូអនុនិងវិទ្យាល័យមិត្តភាពខ្មែរ-ជប៉ុន ពីមន្ត្រីក្រសួងអប់រំ យុវជននិងកីឡាគ្រប់លំដាប់ថ្នាក់ ព្រមទាំងអាជ្ញាធរមូលដ្ឋានទាំងមូលផងទេ នោះរូបខ្ញុំបាទនឹងពុំមានមុខមកទទួ លយកគ្រឿងឥស្សរិយសដ៏មានតម្លៃនេះបានឡើយ។

នៅទីបញ្ចប់ខ្ញុំសូមសំដែងនូវអំណរគុណដ៏ជ្រាលជ្រៅបំផុតជាថ្មីម្តងទៀតចំពោះភ្ញៀវជាតិ និងអន្តរជាតិដែលបានអញ្ជើញមកចូលរួមអបអរសាទរដល់រូបខ្ញុំបាទក្នុងពិធីនេះ។

សូមជួបតែសេចក្តីសុខចំរើនគ្រប់ពេលវេលា

សូមអរគុណ.